01247573

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 31 / 05 / 2016
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

E410

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើចម្លើយមុនៗរបស់សាក្សីដែលមានរហស្សនាម 2-TCW-816

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើដោយផ្ទាល់មាត់របស់មេធាវីការពារក្តី នួន ជា សុំឱ្យទទួលយកកំណត់ហេតុស្តួរចម្លើយសាក្សី 2-TCW-816 របស់តុលាការយោធា ដែលបានធ្វើឡើងនៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩ (ឯកសារ D288/6.52/4.19)។ ដោយឡែក តាម *គំនិតផ្តួចផ្តើមរបស់ខ្លួន* អង្គជំនុំជម្រះបានសម្រេចទទួលយកនូវប្រវត្តិរូបផ្ទាល់ខ្លួនដែលសរសេរដោយសាក្សី 2-TCW-816 កាលពីថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ ១៩៧៧ (ERNs 01241619-01241627)។

២. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានផ្ញើសារអេឡិចត្រូនិកទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយបានធ្វើសេចក្តីសន្និដ្ឋានផ្លូវច្បាប់អំពីភាពអាចទទួលយកបាននៃឯកសារចំនួនពីរ និង បានស្នើសុំធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ស្តីអំពីបញ្ហានេះថែមទៀត។ អង្គជំនុំជម្រះបានយល់ស្របតាមសំណើរបស់មេធាវីការពារក្តីដែល

ស្នើសុំធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់ ហើយនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី នួន ជា និង ចម្លើយតបពីភាគីផ្សេងៗទៀត។ នៅក្នុងសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់របស់ខ្លួន មេធាវីការពារក្ដី នួន ជា ពីដំបូងបានស្នើសុំឱ្យទទួលយកបណ្ដុំឯកសារមួយរបស់មន្ទីរសន្ដិសុខ ស-២១ បន្ថែមពីលើកំណត់ហេតុសួរចម្លើយរបស់តុលាការយោធា ប៉ុន្ដែមេធាវីការពារក្ដីបានដកសំណើនេះចេញវិញ ដោយសារមានការបញ្ជាក់បំភ្លឺពីសហព្រះរាជអាជ្ញាថា ឯកសារពីមន្ទីរសន្ដិសុខ ស -២១ ទាំងនេះ ត្រូវបានទទួលយករួចហើយ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ (ភាសាអង់គ្លេស) ទំព័រ ៤, ៧-៨, ២២ (សេចក្ដីព្រាង))។ ហេតុដូច្នេះ សំណើតែមួយគត់ដែលរង់ចាំការសម្រេចនោះ គឺពាក់ព័ន្ធនឹងកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅតុលាការយោធា។ សហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង មេធាវីការពារក្ដី ខៀវ សំផន មិនជំទាស់ទៅនឹងការទទួលយកឯកសារនេះទេ។

៣. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះ តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន បានជូនដំណឹងដល់ភាគីទាំងអស់តាមសារអេឡិចត្រូនិកថា អង្គជំនុំជម្រះបានទទួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និង បានដាក់ទៅក្នុងឃ្លាំងផ្ទុកឯកសាររួម នូវ "ប្រវត្តិរូបសង្ខេបផ្ទាល់ខ្លួនដែលបានធ្វើឡើងដោយសាក្សី 2-TCW-816 (សូមមើល David Chandler សំឡេងពីមន្ទីរសន្ដិសុខ ស-២១ ឯកសារ E3/1684 ត្រង់ ERN 00191857-00191858)។ ដោយសារតែឯកសារនេះអាចរកមើលបានតែជាភាសាខ្មែរនោះ អង្គជំនុំជម្រះបានស្នើសុំឱ្យមានការបកប្រែឯកសារនេះ និង បានជូនដំណឹងដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងសម្រេចលើភាពអាចទទួលយកបាននៃឯកសារនេះ *តាមឆន្ទានុសិទ្ធិរបស់ខ្លួន*។

៤. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយក នៅគ្រប់ដំណាក់កាលទាំងអស់នៃសវនាការ នូវភ័ស្ដុតាងទាំងអស់ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍ដល់ការស្វែងរកការពិត ប៉ុន្ដែភ័ស្ដុតាងនោះក៏ត្រូវបំពេញផងដែរនូវបទដ្ឋាន*បឋម*នៃភាពជាប់ពាក់ព័ន្ធ ភាពគួរឱ្យជឿជាក់បាន និង យថាភាពដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសម្រេចទៅលើខ្លឹមសារនៃសំណើសុំឱ្យទទួលយកភ័ស្ដុតាងថ្មី អនុលោមតាមលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងតម្រូវថា គ្រប់ភាគីដែលបានស្នើសុំ ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំ

នេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភ័ស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ឬ ភ័ស្តុតាងនោះ នៅពុំទាន់រកឃើញនៅឡើយ បើទោះជាខ្លួនខិតខំព្យាយាមយ៉ាងណាក្តី។ ទោះបីយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន អង្គជំនុំជម្រះធ្លាប់បានទទួលយកភ័ស្តុតាងដែលពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យនេះ ក្នុងនោះរួមមាន ភ័ស្តុតាងដែលពាក់ព័ន្ធយ៉ាងខ្លាំងនឹងសម្ភារៈដែលបានដាក់រួចរាល់ហើយនៅចំពោះមុខអង្គជំនុំជម្រះ និង នៅពេលដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យវាយតម្លៃរួមគ្នាលើប្រភពនៃភ័ស្តុតាង និង នៅពេលដែលភ័ស្តុតាងដែលស្នើឡើងនោះ គឺជាប្រភេទភ័ស្តុតាងដោះបន្ទុក ហើយតម្រូវឱ្យមានការវាយតម្លៃរួមគ្នាដើម្បីជៀសវាងនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E276/2 កថាខណ្ឌ ២ ដែលយោងទៅលើឯកសារ E190 និង ឯកសារ E172/24/5/1, ឯកសារ E260 កថាខណ្ឌ ៥)។

៥. ចំពោះកំណត់ហេតុស្តាប់ចម្លើយរបស់តុលាការយោធាវិញ អង្គជំនុំជម្រះពុំបានពិចារណាអំពីទឡ្ហីករណ៍ផ្លូវច្បាប់ដែលបានលើកឡើងនៅក្នុងសារអេឡិចត្រូនិកនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៦ របស់មេធាវីការពារក្តី នួន ជា ឡើយ។ ការដាក់សំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងតាមរយៈសារអេឡិចត្រូនិក គឺមិនសមស្របតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារឡើយ ហើយមិនមានការស្នើសុំការអនុញ្ញាតឱ្យអនុវត្តប្រាសចាកពីទម្លាប់អនុវត្តដែលបានបង្កើតឡើងនោះដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាតែទៅលើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ពាក់ព័ន្ធនឹងឯកសារនេះប៉ុណ្ណោះ។ ទាក់ទិននឹងរយៈពេលនៃសំណើនេះវិញ អង្គជំនុំជម្រះកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយរបស់តុលាការយោធាមាននៅក្នុងសំណុំរឿងតាំងពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ មកម្ល៉េះ ហើយភាគីទាំងអស់បានទទួលការជូនដំណឹងតាមសារអេឡិចត្រូនិក នៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦ ថា សាក្សី 2-TCW-816 ត្រូវបានជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មលើប្រធានបទមន្ទីរសន្តិសុខ ស-២១។ មេធាវីការពារក្តី នួន ជា ខកខានមិនបានលើកឡើងនូវហេតុផលណាមួយចំពោះការដាក់សំណើរបស់ខ្លួននៅមុនការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះឡើយ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើនេះដាក់មិនបានទាន់ពេលវេលាឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ជាទម្លាប់អនុវត្ត អង្គជំនុំជម្រះបានទទួលយកជាភ័ស្តុតាងនូវរាល់ចម្លើយពីមុនរបស់សាក្សីដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E319/36/2 កថាខណ្ឌ ១៥)។ កំណត់ហេតុស្តាប់ចម្លើយនោះ មានសញ្ញាសម្គាល់ជា

ឯកសារផ្លូវការរបស់តុលាការយោធា និង ស្នាមមេដៃរបស់សាក្សី។ *តាមការវិភាគបឋម* ឯកសារនេះមានភាពជាប់ពាក់ព័ន្ធ និង គួរឱ្យជឿជាក់បាន (រួមទាំងយថាភាពផងដែរ)។ អង្គ-ជំនុំជម្រះយល់ឃើញថា វាជាប្រយោជន៍នៃយុត្តិធម៌ក្នុងការទទួលយកឯកសារនេះ។ ឯកសារទាំងអស់របស់សាក្សីរូបនេះ អាចត្រូវបានវាយតម្លៃរួមគ្នា។

៦. ទាក់ទិននឹងប្រវត្តិរូបផ្ទាល់ខ្លួនរបស់សាក្សីវិញ អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារនេះគឺជាឯកសារសរសេរដោយដៃ និង មានចុះហត្ថលេខាដោយសាក្សី 2-TCW-816។ ឯកសារនេះត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឱ្យអង្គជំនុំជម្រះ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា *តាមការវិភាគបឋម* ឯកសារនេះមានភាពជាប់ពាក់ព័ន្ធ និង គួរឱ្យជឿជាក់បាន (រួមទាំងយថាភាពផងដែរ)។ មានការស្នើសុំឱ្យបកប្រែឯកសារនេះរួចហើយ ហើយសំណៅបកប្រែនឹងផ្តល់ជូនទៅភាគីទាំងអស់ ក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន។

៧. អាស្រ័យហេតុនេះ អង្គជំនុំជម្រះទទួលយកជាឯកសារភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី 2-TCW-816 ដែលបានធ្វើឡើងនៅតុលាការយោធា និង ប្រវត្តិរូបផ្ទាល់ខ្លួនរបស់សាក្សី 2-TCW-816 នេះ ដោយដាក់លេខឯកសារទាំងនេះជាឯកសារ E3/10568 និង E3/10570។